ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាទីគោរព!

នាងខ្ញុំ សូមសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះការចូលរួមរបស់ **ឯកឧត្តម ឯកអគ្គរាជទូត ជុំ សុន្ទរី** នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី៥០ របស់សម្ព័ន្ធជាតិនៃគ្រួសារទាហានអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៩-២២ ខែមិថុនា ឆ្នាំ២០១៩នេះ នៅស្រុកអាលីងថុន រដ្ឋវីជីននៀ។ នៅរសៀល ថ្ងៃព្រហស្បតិ៍ ទី២០ មិថុនា **ឯកឧត្តម ឯកអគ្គរាជទូត** បានថ្លែងពីចំណាប់អារម្មណ៍របស់រាជរដ្ឋាភិបាលកម្ពុជាទៅលើបេសកកម្មរុករកអដ្ឋិធាតុទាហានអាមេរិកនេះ ចំពោះមុខក្រុមគ្រួសារយុទ្ធជន និងមន្ត្រីអាមេរិកទាំងឡាយ។ ឯកឧត្តម ឯកអគ្គរដ្ឋទូតឡាវ និងវៀតណាមក៏បានអញ្ជើញចូលរួមជាមួយ **ឯកឧត្តម ឯកអគ្គរាជទូត** ក្នុងកម្មវិធីនេះផងដែរ ។

**ឯកឧត្តម ឯកអគ្គរាជទូត ជុំ សុន្ទរី** បានថ្លែងសុន្ទរកថា ប្រកបដោយពុទ្ធិ ដោយលើកឡើងអំពីរឿងពិតនៃកិច្ចសហប្រតិបត្តិការដ៏យូរអង្វែងរបស់ប្រទេសយើងទាំងពីរ ដូចជា ប្រទេសកម្ពុជាត្រូវបានគេទទួលស្គាល់ជាយូរមកហើយថា ជាដៃគូសហការកម្រិត Gold Standard ក្នុងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការក្នុងបេសកកម្មរុករកអដ្ឋិធាតុនេះ។ ក្រុមគ្រួសារជនរងគ្រោះ បានសម្តែងការពេញចិត្តចំពោះសុន្ទរកថារបស់ **ឯកឧត្តម ឯកអគ្គរាជទូត** ដោយបានបន្លឺស្នូរទះដៃយ៉ាងកងរំពងជូនចំពោះ **ឯកឧត្តម ឯកអគ្គរាជទូត** និងសហការីផងដែរ ។

នៅពេលដែលសហរដ្ឋអាមេរិក បានចូលរួមជាអ្នកសម្របសម្រួលក្នុងការចរចាកិច្ចព្រមព្រៀងសន្តិភាពនៅកម្ពុជាកន្លងមក **សម្តេច** ប្រហែលជាអាចនៅចាំបានថា នាងខ្ញុំធ្លាប់ធ្វើការជាមួយលោក ឌីក សូលោមុណ (Dick Solomon) ឧបការីទទួលបន្ទុកកិច្ចការអាស៊ី និងប៉ាស៊ីហ្វិក ដែលលោកបានដឹកនាំគណៈប្រតិភូក្រោយការផ្សះផ្សាជាតិមកភ្នំពេញលើកដំបូង កាលពីឆ្នាំ១៩៩២។ ពិតណាស់ នាងខ្ញុំបានធ្វើការដោយផ្ទាល់ជាមួយ **សម្តេច** មុនពេលដែលលោក សូលោមុណ បានចូលកាន់តំណែងមកម្ល៉េះ ម្ល៉េះហើយប្រវត្តិនៃកិច្ចសហការនៅក្នុងបេសកកម្មរុករកអដ្ឋិធាតុរបស់យើងនេះ គឺពិតជាមានភាពយូរអង្វែងពិតមែន ។

យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេច** ដែលបានចាត់តាំងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ឲ្យដឹកនាំគណៈកម្មការកម្ពុជាសម្រាប់ការរុករកអដ្ឋិធាតុទាហានអាមេរិកនេះ។ បើទោះបីជារាជរដ្ឋាភិបាលក្នុងអាណត្តិថ្មីបានផ្លាស់ប្តូរសមាជិកក៏ដោយ ក៏អតីតអគ្គមេបញ្ជាការ **ឯកឧត្តម ប៉ុល សារឿន** នៅតែបន្តតំណែងជាប្រធានគណៈកម្មការនេះដដែល ដែលកិច្ចសហការរបស់យើងខ្ញុំជាមួយ **ឯកឧត្តម អគ្គមេបញ្ជាការ** តែងតែប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងផ្លែផ្ការហូតមក ដូចដែលយើងធ្លាប់បានធ្វើការជាមួយ **ឯកឧត្តម សៀង ឡាប្រេស្ស** និង **លោកឧត្តមសេនីយ៍ឯក ជុំ សូយ៉ាត** ព្រមទាំងមានការចូលរួមពីសមាជិកក្រុមកម្ពុជាទាំងអស់ផងដែរ ។

ជាទីបញ្ចប់ នាងខ្ញុំសង្ឃឹមថានឹងអាចបន្តធ្វើការឲ្យកាន់តែជិតស្និទ្ធបន្ថែមទៀតជាមួយ **ឯកឧត្តម ឯកអគ្គរាជទូត ជុំ សុន្ទរី** ក្នុងបេសកកម្មការទូតរបស់ **ឯកឧត្តម ឯកអគ្គរាជទូត** ដែលកំពុងបន្តរីកចម្រើន នៅក្នុងការបំពេញភារកិច្ច នៅរដ្ឋវ៉ាស៊ីងតោននេះ ។

សូមប្រសិទ្ធិពរបវរមហាប្រសើរ ជូនចំពោះ **សម្តេច** និងដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត

**អាន មីល ហ្គ្រីហ្វីត**

ប្រធានសម្ព័ន្ធគ្រួសាររបស់ឈ្លើយសឹក និង

ទាហានអាមេរិកបាត់ខ្លួននៅអាស៊ីអាគ្នេយ៍